គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សូមគោរពជូន**

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**តាមរយៈ** : **ឯកឧត្តម អគ្គលេខាធិការ គ.ជ.ប.ជ**

**កម្មវត្ថុ** : សំណើសុំតែងតាំង លោកវរសេនីយ៍ទោ **អ៊ិន មាន** ពីអនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ទៅជាប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិស្តីទី ។

សេចក្តីដូចមានចែងតាមកម្មវត្ថុខាងលើ នាងខ្ញុំសូមគោរពជម្រាបជូន **លោកជំទាវ** មេត្តាជ្រាបថា៖ ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ កំពុងខ្វះប្រធានក្រុមដឹកនាំការងារចំពោះមុខ ដូច្នេះនាងខ្ញុំស្នើតែងតាំង លោកវរសេនីយ៍ទោ **អ៊ិន មាន** ពីអនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ទៅជាប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិស្តីទី នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជំនួសលោកឧត្តមសេនីយ៍ត្រី **សុខ រស្មី** ដែលត្រូវបានប្រកាសតែងតាំងទទួលភារកិច្ចថ្មី ជាអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ តាមអនុក្រឹត្យលេខ ១២៩៧ អនក្រ.តត ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់រាជរដ្ឋាភិបាលកម្ពុជា ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ រហូតដល់មានការតែងតាំងប្រធានក្រុមការងារសហប្រតិបត្តិការអន្តរជាតិថ្មី ។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **លោកជំទាវ** មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតដោយក្តីអនុគ្រោះ។

សូម **លោកជំទាវ** មេត្តាទទួលនូវការគោរពពីនាងខ្ញុំ៕

ថ្ងៃ អង្គារ ២កើត ខែ បុស្ស ឆ្នាំ រកា នព្វស័ក ពស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០១៧
**អគ្គលេខាធិការរងទទួលបន្ទុក**

**វ៉ែន_សិរីលក្ខិណា**

ឯកភាព
19/12/17

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

## សូមគោរពជូន

## ឯកឧត្តម អគ្គលេខាធិការ គ.ជ.ប.ជ

**កម្មវត្ថុ** : សំណើសុំតែងតាំង លោកវរសេនីយ៍ទោ **អ៊ិន មាន** ពីអនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ទៅជាប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិស្តីទី ។

សេចក្តីដូចមានចែងតាមកម្មវត្ថុខាងលើ នាងខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តម អគ្គលេខាធិការ** មេត្តាជ្រាបថា៖ ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ កំពុងខ្វះប្រធានក្រុមដឹកនាំការងារចំពោះមុខ ដូច្នេះនាងខ្ញុំស្នើតែងតាំង លោកវរសេនីយ៍ទោ **អ៊ិន មាន** ពីអនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ទៅជាប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិស្តីទី នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជំនួសលោកឧត្តមសេនីយ៍ត្រី **សុខ រស្មី** ដែលត្រូវបានប្រកាសតែងតាំងទទួលភារកិច្ចថ្មី ជាអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ តាមអនុក្រឹត្យលេខ ១២៩៧ អនក្រ.តត ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់រាជរដ្ឋាភិបាលកម្ពុជា។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តម អគ្គលេខាធិការ** មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម អគ្គលេខាធិការ** មេត្តាទទួលនូវការគោរពពីនាងខ្ញុំ៕

ថ្ងៃ អង្គារ ២កើត ខែ បុស្ស ឆ្នាំ រកា នព្វស័ក ពស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០១៧
**អគ្គលេខាធិការរងទទួលបន្ទុក**

**ខែ សិរីលក្ខិណា**

19.12.2017

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១២៩៧ អនក្រ.តត

# អនុក្រឹត្យ

## ស្ដីពី

## ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

មាត្រា ១ : តែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ត្រី **សុខ ស៊ើ** អត្តលេខ ០៥៤៧៤ ពីអគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស(គ.ជ.ប.ជ) ទៅជាអនុប្រធាននាយកដ្ឋានកណ្ដាលនគរបាលយុត្តិធម៌ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៧,

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ